**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ:០១១/២៦.សជណ

ថ្ងៃសុក្រ ៣កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបម្រើសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុង ដោយមិនបង់ប្រាក់ រយៈពេល ០៦ថ្ងៃ ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៦ នៅក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០

រដ្ឋបាលរាជធានីភ្នំពេញ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ មេត្តាជ្រាបថា ដោយអនុវត្តតាមប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី១១ នាថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៦ រដ្ឋបាលរាជធានីភ្នំពេញ នឹងរៀបចំរថយន្តក្រុងចំនួន ៦០០គ្រឿង សម្រាប់បម្រើសេវាដឹកជញ្ជូនសាធារណៈដោយមិនបង់ប្រាក់រយៈពេល ០៦ថ្ងៃ ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៦ ដើម្បីជួយសម្រួលដល់ការចំណាយរបស់បងប្អូនប្រជាពលរដ្ឋទាំងអស់ ក្នុងការធ្វើដំណើរទៅលេងស្រុកកំណើត ជួបជុំបងប្អូនក្រុមគ្រួសារ ក្នុងឱកាសអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ ដោយក្នុងនោះរួមមាន៖

១-សេវាដឹកជញ្ជូនប្រជាពលរដ្ឋក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងសេវារថយន្តក្រុងអាកាសយានដ្ឋានអន្តរជាតិតេជោ(Airport Express Bus)៖ ប្រើប្រាស់រថយន្តក្រុងចំនួន ១០០គ្រឿង ។

២-សេវាដឹកជញ្ជូនប្រជាពលរដ្ឋធ្វើដំណើរពីរាជធានីភ្នំពេញទៅតាមបណ្តាខេត្ត និងពីបណ្តាខេត្តត្រឡប់ចូលមករាជធានីភ្នំពេញវិញ៖ ប្រើប្រាស់រថយន្តក្រុងចំនួន ៥០០គ្រឿង ដោយមានបែងចែកជាខ្សែរត់ធំៗ ចំនួន ៦គោលដៅ ព្រមទាំងបានរៀបចំទឹកពិសាបរិសុទ្ធដោយឥតគិតថ្លៃនៅក្នុងរថយន្តក្រុងនីមួយៗតាមគោលដៅចេញដំណើរ ដែលមានព័ត៌មានលម្អិត ដូចខាងក្រោម៖

| ល.រ | គោលដៅ | ចំនួនរថយន្ត | ទីតាំង និងម៉ោងចេញដំណើរ<br>ភ្នំពេញ - ខេត្ត - ភ្នំពេញ<br>ចាប់ពីម៉ោង ៦:៣០នាទីព្រឹក ដល់ម៉ោង ១១:៣០នាទីព្រឹក | |
|---|---|---|---|---|
| ១ | ភ្នំពេញ-ព្រៃវែង-ភ្នំពេញ | ០៥ គ្រឿង | ស្ថានីយរថយន្តក្រុងវាលស្បូវ<br>(ផ្លូវជាតិលេខ១ ច្រកចូលបុរីគោកសំណាង) | ចំណតទីរួមខេត្តព្រៃវែង |
| | ភ្នំពេញ-ស្វាយរៀង-ភ្នំពេញ | ១៥ គ្រឿង | | ចំណតទីរួមខេត្តស្វាយរៀង |
| ២ | ភ្នំពេញ-កណ្តាល-តាកែវ-ភ្នំពេញ | ០៣ គ្រឿង | ស្ថានីយរថយន្តក្រុងចាក់អង្រែលើ | ចំណតរង្វង់មូលអូរចំបក់ |
| ៣ | ភ្នំពេញ-កែប-ភ្នំពេញ | ០៩ គ្រឿង | ស្ថានីយរថយន្តក្រុងផ្លូវ២០០៤<br>(ជាប់របងបញ្ជាការដ្ឋានកងទ័ពអាកាស) | សាលាបឋមសិក្សាដំណាក់ចង្អើរ |
| | ភ្នំពេញ-កំពត-ភ្នំពេញ | ០៩ គ្រឿង | | ចំណតរថយន្តទីរួមខេត្តកំពត |
| | ភ្នំពេញ-កំពង់ស្ពឺ-ព្រះសីហនុ-ភ្នំពេញ | ១៤ គ្រឿង | | វិមានឯករាជ្យ ខេត្តព្រះសីហនុ |
| | ភ្នំពេញ-កំពង់ស្ពឺ-កោះកុង-ភ្នំពេញ | ០៥ គ្រឿង | | សាលាខេត្តកោះកុង |



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

| | | | | |
|---|---|---|---|---|
| ៤ | ភ្នំពេញ-កំពង់ឆ្នាំង-ភ្នំពេញ | ១០ គ្រឿង | ស្ថានីយរថយន្តក្រុងសួនច្បារឫស្សីកែវ | ចំណតរថយន្តផ្សារលើ |
| | ភ្នំពេញ-ពោធិ៍សាត់-ភ្នំពេញ | ២០ គ្រឿង | | ទីតាំងបុរីឧកញ៉ា ភូ ពុយ |
| | ភ្នំពេញ-បាត់ដំបង-ភ្នំពេញ | ៧៥ គ្រឿង | | ចំណតរថយន្តផ្សារទំនើប ភូ ពុយ |
| | ភ្នំពេញ-បន្ទាយមានជ័យ-ភ្នំពេញ | ៦៥ គ្រឿង | | ចំណតរថយន្តក្រុងសេរីសោភ័ណ្ឌ |
| | ភ្នំពេញ-ប៉ៃលិន-ភ្នំពេញ | ២០ គ្រឿង | | សាលាខេត្តប៉ៃលិន |
| ៥ | ភ្នំពេញ-កំពង់ធំ-ភ្នំពេញ | ១៥ គ្រឿង | ដីឡូត៍តំបន់ OCIC ជ្រោយចង្វារ (រង្វង់មូលទេពមច្ឆា) | ចំណតរថយន្តខេត្តកំពង់ធំ នៅវិថីប្រជាធិបតេយ្យ ខាងកើតវិមានឯករាជ្យ (ក្រោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) |
| | ភ្នំពេញ-សៀមរាប-ភ្នំពេញ | ១១៥ គ្រឿង | | បុរីរដ្ឋបាលខេត្តសៀមរាប វិថីសម្តេចវិបុលបញ្ញា សុខ អាន (ផ្លូវ៦០ម៉ែត្រ) |
| | ភ្នំពេញ-ឧត្តរមានជ័យ-ភ្នំពេញ | ១៥ គ្រឿង | | មុខវេទិកាបុណ្យអុំទូក ខេត្តឧត្តរមានជ័យ |
| | ភ្នំពេញ-ព្រះវិហារ-ភ្នំពេញ | ១០ គ្រឿង | | សាលាក្រុងព្រះវិហារ |
| ៦ | ភ្នំពេញ-កំពង់ចាម-ភ្នំពេញ | ១៨ គ្រឿង | ស្ថានីយរថយន្តក្រុង រង្វង់មូលក្បាលកណ្តុង | ចំណតរថយន្តខេត្តកំពង់ចាម |
| | ភ្នំពេញ-ត្បូងឃ្មុំ-ភ្នំពេញ | ១២ គ្រឿង | | ចំណតផ្សារសួង |
| | ភ្នំពេញ-ក្រចេះ-ភ្នំពេញ | ២៥ គ្រឿង | | មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត (រង្វង់មូលព្រាប ស) |
| | ភ្នំពេញ-ស្ទឹងត្រែង-ភ្នំពេញ | ២០ គ្រឿង | | សាលាខេត្តស្ទឹងត្រែង |
| | ភ្នំពេញ-មណ្ឌលគិរី-ភ្នំពេញ | ១០ គ្រឿង | | រង្វង់មូលគោព្រៃ |
| | ភ្នំពេញ-រតនគិរី-ភ្នំពេញ | ១០ គ្រឿង | | ចំណតរថយន្តតាយសេង |

ឆ្លៀតក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ **រដ្ឋបាលរាជធានីភ្នំពេញ** សូមអំពាវនាវដល់ម្ចាស់ក្រុមហ៊ុន ម្ចាស់អាជីវកម្ម និងម្ចាស់រថយន្តដឹកជញ្ជូនអ្នកដំណើរទាំងអស់ សូមផ្តល់កិច្ចសហការរក្សាតម្លៃសេវាដឹកជញ្ជូនឱ្យនៅដដែល **ដោយពុំដំឡើងថ្លៃ** ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ ខាងមុខនេះ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល និងរដ្ឋបាលរាជធានីភ្នំពេញ ក្នុងការជួយសម្រួលដល់ការចំណាយ និងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ។

អាស្រ័យហេតុនេះ សូមបងប្អូនកម្មករ-និយោជិត និងប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាប និងចូលរួមធ្វើដំណើរទៅលេងស្រុកកំណើត ជួបជុំបងប្អូនក្រុមគ្រួសារ ជាពិសេស ទៅលេងកម្សាន្តនៅតាមបណ្តាខេត្តនានា តាមរយៈរថយន្តក្រុង របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៦ ប្រកបដោយសុវត្ថិភាព និងផាសុកភាពទាំងអស់គ្នា៕

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  "ដើម្បីគោរពជូនជ្រាប"
- រដ្ឋបាលខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប និងផ្តល់កិច្ចសហការ"
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង១៤
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ
  "ដើម្បីសហការ"
- រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ
  "ដើម្បីអនុវត្ត"
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

សូមស្កេនទីនេះ
ដើម្បីទទួលបានព័ត៌មាន អំពីទីតាំងចេញដំណើរ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh